## ៧. ការពិគ្រោះយោបល់សាធារណៈ

**១៨៧.** ការពិគ្រោះយោបល់សាធារណៈ ជាមួយថ្នាក់ដឹកនាំខេត្ត ស្រុក ឃុំ ភូមិ និងប្រជាជន សហគមន៍ដែលពាក់ព័ន្ធ បានរៀបចំធ្វើឡើងនៅក្នុងដំណើរការរៀបចំរបាយការណ៍ ដើម្បីធ្វើការព្យាករណ៍ អំពីហេតុប៉ះពាល់ និងផ្តល់នូវអនុសាសន៍ជាមូលដ្ឋាន។ សមាសភាពដែលបានចូលរួមពិគ្រោះយោបល់មាន : អភិបាលខេត្តកំពង់ធំ អភិបាលរងខេត្តកំពង់ធំ អនុប្រធានមន្ទីររៀបចំដែនដីនគរូបនីយកម្ម និងសំណង់ខេត្តកំពង់ធំ អនុប្រធានការិយាល័យ EIA មន្ទីរបរិស្ថាន ខេត្តកំពង់ធំ អនុប្រធានមន្ទីរកសិកម្មខេត្តកំពង់ធំ នាយរងខណ្ឌរដ្ឋបាលព្រៃឈើ ខេត្តកំពង់ធំ អគ្គលេខាធិការរងខេត្តសាលាខេត្ត ជំនួយការអភិបាលខេត្តកំពង់ធំ អភិបាលស្រុក ស្ទោង សរុបចំនួន ០៨ នាក់ កាលពី ថ្ងៃទី ០៧ ខែ មិថុនា ឆ្នាំ២០១០ (ឧបសម្ព័ន្ធ៧: **តារាង៧-១**) របាយការណ៍កំណត់ហេតុពិគ្រោះយោបល់សូមអាននៅទំព័រទី១៣៥-១៥១ និងរូបភាពប្រជុំមាននៅក្នុង **ឧបសម្ព័ន្ធ ៧-៣**។ ក្រុមការងារ GCF របស់ **ហ្គ្រីនខិនសាល់ធិនស៊ីហ្វឹម** ក៏បានចុះទៅដល់មូលដ្ឋាន ដើម្បីធ្វើការពិភាក្សា និងពិគ្រោះយោបល់ជាមួយ មេឃុំ សមាជិកក្រុមប្រឹក្សាឃុំ មេភូមិ និងប្រជាសហគមន៍ ដែលរស់នៅពាក់ព័ន្ធក្នុងតំបន់គំរោងសរុបចំនួន ២៨ នាក់ ថ្ងៃទី ២៩ ខែ ឧសភា ដល់ថ្ងៃទី ០៣ ខែ មិថុនា ឆ្នាំ២០១០ (**ឧបសម្ព័ន្ធ ៧ : តារាង៧**-២ និង រូបភាព នៅក្នុង**ឧបសម្ព័ន្ធ៧-៣**)។

**របាយការណ៍សង្ខេបស្តីពីការពិគ្រោះយោបល់ជាមួយអាជ្ញាធរឃុំ លើការងារវាយតំលៃហេតុប៉ះពាល់បរិស្ថាន និងសង្គម**

**របាយប្រជាជន**

**១៨៨.** ក្រុមការងារធ្វើការសិក្សាវាយតំលៃអំពីស្ថានភាពជីវភាពរស់នៅរបស់ប្រជាពលរដ្ឋ ក្នុងភូមិសាស្ត្រ ដែលក្រុមហ៊ុន C.R.C.K.2 APHIVATH CAOUT CAOUC CO., LTD. បានស្នើសុំមាន ទីតាំងស្ថិតក្នុងឃុំពពក ស្រុក ស្ទោងខេត្តកំពង់ធំ។ ឃុំពពកមានភូមិចំនួន៨គឺ: (១) ភូមិសំបួរ មាន១៨១គ្រួសារ (៩១៥នាក់) ស្រី ៤៩៩នាក់ (២)ភូមិអន្លង់ក្រាញ់មាន ៣៣៩ គ្រួសារ (១៩១២នាក់) ស្រី ៩៦៩នាក់ (៣) ភូមិកោះសំរោង មាន៤០គ្រួសារ (២៣៨នាក់) ស្រី ១៣១នាក់ (៤) ភូមិស្រែក្រសាំងមាន ២៨៦គ្រួសារ (១៧០២នាក់) ស្រី ៨៧១នាក់ (៥) ភូមិខ្ទមមន មាន ១០៩គ្រួសារ (៥៩២នាក់) ស្រី ២៨២នាក់ (៦)ភូមិពពក ៣២១គ្រួសារ (១៨៨៧នាក់) ស្រី ១០២៣នាក់ (៧) ភូមិផ្ទះដើម មាន ៧០គ្រួសារ (៤១៤នាក់) ស្រី ២២៥នាក់ (៨) ភូមិត្រពាំងឬស្សី មាន ១២០គ្រួសារ (៨៩២នាក់) ស្រី ៦០២នាក់ ដូចនេះប្រជាជនសរុបទូទាំងឃុំមានចំនួន ៨៥៤៩នាក់ ក្នុងនោះមាន ស្រី ៤៦០៦នាក់ (តារាងស្ថិតិប្រជាពលរដ្ឋឃុំពពក ឆ្នាំ២០១០)។ ចំពោះភូមិដែលពាក់ព័ន្ធដីសម្បទានសេដ្ឋកិច្ច ដែលក្រុមហ៊ុន C.R.C.K.2 APHIVATH CAOUT CAOUC CO.,



Draft

LTD. ស្នើសុំគឺមានពាភូមិគឺ ភូមិសំបូរ និងភូមិពពក និងភូមិកោះសំរោង តែក្រុមហ៊ុនបានធ្វើការដោះស្រាយដីពាក់ព័ន្ធរួចស្រេចអស់ហើយ (តាមការផ្តល់ពត៌មានពីក្រុមប្រឹក្សាឃុំក៏ដូចជាប្រជាពលរដ្ឋក្នុងពេលប្រជុំពិគ្រោះយោបល់)។

**តារាងស្ថិតិប្រជាពលរដ្ឋឆ្នាំ ២០០៩ ឃុំពពក**

| ល.រ | ឈ្មោះភូមិ | ចំនួនគ្រួសារ | ចំនួនប្រជាពលរដ្ឋសរុប(នាក់) | ចំនួនមនុស្សស្រីសរុប(នាក់) |
|---|---|---|---|---|
| ១ | ភូមិសំបូរ | ១៨១ | ៩១៥ | ៤៩៩ |
| ២ | អន្លង់ក្រាញ់ | ៣៣៩ | ១៩១២ | ៩៦៩ |
| ៣ | កោះសំរោង | ៤០ | ២៣៤ | ១៣១ |
| ៤ | ស្រែក្រសាំង | ២៤៦ | ១៧០២ | ៨៧១ |
| ៥ | ខ្ទមមន | ១០៩ | ៥៩២ | ២៨២ |
| ៦ | ពពក | ៣២១ | ១៨៨៧ | ១០២៣ |
| ៧ | ផ្ទះដើម | ៧០ | ៤១៤ | ២២៥ |
| ៨ | ត្រពាំងឫស្សី | ១២០ | ៨៩២ | ៦០២ |
| សរុបរួម | | ១៤២៦ | ៨៥៤៨ | ៤៦០២ |

**លក្ខណៈប្រជាសាស្ត្រ**

**១៨៩.** លទ្ធផលនៃការសិក្សាបានបង្ហាញអោយឃើញថា ប្រជាពលរដ្ឋរស់នៅក្នុងឃុំពពកភាគច្រើនលើសលប់ជាជនជាតិខ្មែរ ហើយក្រៅពីនោះមានតែមួយគ្រួសារមានគ្នា៣នាក់ប៉ុណ្ណោះដែលមានដើមកំណើតជាជនជាតិចាម ពួកគាត់សុទ្ធតែចេះនិយាយ ភាសាខ្មែរទាំងអស់គ្នា ហើយម្យ៉ាងទៀតពួកគាត់ប្រកាន់ប្រពៃណីវប្បធម៌របស់គាត់តែអ្វីគួរអោយកត់សំគាល់ទេ ពួកគាត់ជាទូទៅ និយាយភាសាខ្មែរ លើកលែងតែពេលនិយាយជាមួយជនជាតិគ្នាគាត់តែប៉ុណ្ណោះ ដែលនិយាយចាម។ ការតាំងទីលំនៅរបស់ពួកគាត់គឺ: (១)តាមទីប្រជុំជនឃុំ (២)តាមណ្តោយផ្លូវលំនៅតាមភូមិពីភូមិមួយ ទៅភូមិមួយមានលក្ខណៈជាជួរបន្ទាត់។

**១៩០.** ទំនៀមទំលាប់ប្រពៃណី នៃការរស់នៅរបស់ប្រជាជនក្នុងតំបន់នេះមានលក្ខណៈប្រហាក់ប្រហែលគ្នានឹងប្រជាជនរស់នៅតំបន់ផ្សេងៗទៀតនៃតំបន់ទំនាបកណ្តាលដទៃដែរ។ ឧទាហរណ៍ ដូចជាពិធីរៀបអាពាហ៍ពិពាហ៍ គឺធ្វើតាមប្រពៃណីខ្មែរ ដោយការតុបតែង ឬសំអាងការខ្លួនកូនក្រមុំការប្រគុំភ្លេងប្រពៃណី សែនព្រេន និងការអញ្ជើញភ្ញៀវចូលរួមជប់លៀងអាហារ ដើម្បីជូនពរនៅថ្ងៃមង្គលការរបស់កូនកំលោះកូនក្រមុំជាដើម។

តាមការរៀបរាប់របស់ប្រជាពលរដ្ឋឃុំពពក ដើម្បីទុកដាក់កូនចៅឱ្យមានគូរស្រករពួកគាត់ត្រូវចំណាយលុយអស់ប្រហែល៤-៦លានរៀល។ ក្រៅពីនោះ ប្រជាពលរដ្ឋរស់នៅតំបន់នោះនៅមានជំនឿផ្សេងៗទៀត ដូចជាការសែនចំការ និងការបន់ស្រន់ ការសែនព្រេនអ្នកតាទឹក អ្នកតាភ្នំជាដើម។

១៩១. ដោយយោងទៅលើលក្ខណៈរស់នៅ និងការប្រកបរបរចិញ្ចឹមជីវិតដែលពឹងអាស្រ័យទៅលើការធ្វើស្រែ និងចំការនោះ អាចបញ្ជាក់អោយឃើញថា អ្នកដែលជាបង្គោលដើរតួសំខាន់ក្នុងការទ្រទ្រង់ជីវភាពគ្រួសារភាគច្រើនជាបុរសភេទ។ ទោះជាយ៉ាងណាក៏ដោយ ភាពចាំបាច់នៃការរស់នៅត្រូវតែមានការចូលរួមពីស្ត្រីផងដែរ តួយ៉ាងស្ត្រីបានចូលរួមយ៉ាងសំខាន់ក្នុងសកម្មភាពការងារគ្រួសារ នយោបាយ និងសង្គម។ ប៉ុន្តែប្រពៃណី ទំនៀមទំលាប់ និងសង្គមរស់នៅរបស់ប្រជាជននៅតំបន់ជនបទដាច់ស្រយាលទាំងនោះនៅរក្សាខ្ជាប់ខ្ជួនតាមរបៀបបូរាណនៅឡើយទេ។ ក្នុងការប្រជុំពិគ្រោះយោបល់នេះ មានការចូលរួមជាច្រើន ទាំងបុរស និងស្ត្រីដែលស្ថិតនៅក្នុងភាពជាអ្នកនៅលីវ អ្នករៀបការហើយ និងមួយចំនួនទៀតជាស្ត្រីមេម៉ាយ ហើយពួកគាត់ភាគច្រើនមានអាយុស្ថិតនៅចន្លោះពី១៨-៧០ឆ្នាំ។ ទោះបីជាសាលារៀនមាននៅគ្រប់ភូមិក្តី តែមានគ្រួសារខ្លះពួកគាត់មិនបានបញ្ជូនកូនទៅរៀនទេបានគ្រប់គ្នានៅឡើយទេ ដោយសារថាសាលានៅឆ្ងាយហើយ ផ្លូវមានការលំបាកនៅរដូវវស្សា និងបញ្ហាជីវភាពពួកគាត់មានកំណត់នៅឡើយ។

**ស្ថានភាពផ្ទះសម្បែង និងទ្រព្យសម្បត្តិរបស់គ្រួសារ :**

១៩២. តាមលទ្ធផលនៃការសិក្សា និងធ្វើអង្កេតផ្ទាល់ប្រជាជននៅតំបន់នេះ គឺមានជីវភាពរស់នៅជាមធ្យម ប៉ុន្តែសេវាបំរើសុខភាព និងអប់រំពុំទាន់មានលក្ខណៈប្រសើរដូចឃុំផ្សេងទៀតនៃស្រុកស្ទោងនៅឡើយទេ។ ទិន្នន័យ ដែលយើងបានទទួលពីស្មៀនឃុំបានបង្ហាញថា ផ្ទះសម្បែងភាគច្រើនធ្វើពីឈើប្រក់ស្លឹក ក្បឿង ផ្ទះប្រក់ស័ង្កសី និងប្រក់ហ្វីប្រូស៊ីម៉ង់តិ៍ផងដែរ។ ដែលមានទំហំតូចជាងគេគឺ ២០ម$^2$ និងផ្ទះដែលមានទំហំធំជាងគេគឺ ៩០ម$^2$ សង់ខ្ពស់ផុតពីដីកំពស់ពី១.៥-៣ ម៉ែត្រ ផ្ទះធំឬតូចអាស្រ័យទៅនឹងជីវភាពគ្រួសារ។

១៩៣. ការចុះអង្កេតជាក់ស្តែងបានបង្ហាញអោយឃើញថា ប្រជាពលរដ្ឋទាំងនោះរស់នៅ តាមភូមិចាស់ តាមផ្លូវចូលទៅក្រាលគ្រួសក្រហម និងកន្លែងខ្លះជាផ្លូវលំ ដូចនេះពួកគាត់ប្រើប្រាស់ម៉ូតូ ឬពួកគាត់ធ្វើដំណើរថ្មើរជើងតែម្តង។ ក្រៅពីនេះប្រជាពលរដ្ឋតាមភូមិក្នុងឃុំពពក មួយចំនួនមានការប្រើប្រាស់ឧបករណ៍នេសាទត្រី និង អន្ទាក់ដាក់សត្វ។

១៩៤. ចំពោះការប្រើប្រាស់និងការកាន់កាប់ដីធ្លីរបស់ពួកគាត់គឺ ពុំទាន់មានបង្កាន់ដៃ ឬប្លង់កាន់កាប់ត្រឹមត្រូវនៅឡើយទេ ហើយដីលំនៅដ្ឋានដែលពួកគាត់មានជាមធ្យមក្នុងមួយគ្រួសារគឺ ៦០០ម$^2$ ច្រើនតែនៅប្រមូលផ្តុំ

គ្នាមួយកន្លែងដោយទុកប្រឡោះកណ្តាលធ្វើជារោងប្រជុំ និងធ្វើពិធីបុណ្យផ្សេងៗទៅប្រពៃណីរបស់ពួកគាត់។ ចំណែកដីស្រែ ជាមធ្យមក្នុងមួយគ្រួសារៗមាន០.៥-១ហិកតាសំរាប់ធ្វើការដាំដុះ និងបង្កបង្កើនផលដោយពួកគាត់និយមដាំដំណាំ ដូចជាធ្វើស្រែ និងដីចំការដាំស្វាយចន្ទីជាដើម។ តាមរយៈការចុះសិក្សាដោយផ្ទាល់ជាមួយប្រជាពលរដ្ឋនៅទីនោះបង្ហាញថា ផលិតផលចំការស្វាយចន្ទីជាប្រភពចំណូលសំខាន់របស់គ្រួសារនីមួយៗ។ តែផ្ទៃដីសំរាប់ធ្វើស្រែមានតិចតួច មិនអាចផ្តល់ឱ្យគ្រប់គ្រួសារឡើយ គ្រួសារដែលគ្មានដីស្រែបានទៅរានដីធ្វើចំការទៅតាមលទ្ធភាពរៀងៗខ្លួន។ គ្រួសារភាគច្រើនដាំស្វាយចន្ទី ទិន្នផលនៃមុខដំណាំនេះអាចធ្វើឱ្យប្រជាជននៅក្នុងតំបន់នេះមានជីវភាពធូរធារមួយកំរិតក្នុងរយៈពេលពីឆ្នាំមុននេះ(២០០៩) ដែលតំលៃក្នុង១គីឡូក្រាមលក់បានក្នុងតំលៃ២៥០០-៣០០០រៀល។ ក្រៅពីនោះពួកគាត់ប្រកបរបរកាប់អុស និងកាប់ឈើនៅក្នុងតំបន់អភិរក្ស។ ចំណូលដែលបានមកពីការធ្វើចំការ និងចំការស្វាយចន្ទីនេះក៏នៅតែមិនអាចទ្រទ្រង់នូវជីវភាពក្នុងគ្រួសាររបស់ពួកគាត់ល្អទេ ព្រោះគ្រួសារភាគច្រើនមានសមាជិកច្រើន ហើយការដាំដំណាំចន្ទីរបស់ពួកគាត់មានលក្ខណៈជាយថាផល ទិន្នផលស្រូវដែលទទួលបាននៅមានកំរិតទាបនៅឡើយគិតជាមធ្យមគឺ១០-១៥ក្នុងមួយដើមក្នុង១ឆ្នាំមួយហិកតា (៥០០-៧០០ដើម/ហិកតា) ដូចនេះ មួយឆ្នាំអាចទទួលបានប្រមាណ ២៥០០ ០០០-៣១៥០០០០រៀល (តាមការសាកសួរជាមួយលោក ជាង តឿ ក្រុមប្រឹក្សាឃុំពពក)។

**១៩៥.** ការប្រើប្រាស់មធ្យោបាយអូសទាញក្នុងការធ្វើកសិកម្មរបស់អ្នកភូមិនៅក្នុងឃុំពពកទាំងមូលដែរ ពឹងផ្អែកទៅលើគោ-ក្របី ដែលជាកំលាំងអូសទាញទាំងស្រុង ហើយការធ្វើស្រែចំការរបស់គាត់ នៅមានលក្ខណៈយថាផលដោយពឹងផ្អែកលើទឹកភ្លៀងទាំងស្រុង។ ជាក់ស្តែងនៅក្នុងឃុំពពកទាំងមូល ទោះបីជាការធ្វើស្រែចំការ គឺអាស្រ័យការប្រើប្រាស់ គោ ក្របី ជាកំលាំងសំរាប់ជំនួយក្នុងការធ្វើស្រែចំការក៏ដោយតែគាត់ការចិញ្ចឹមសត្វទាំងនោះសំរាប់លក់ដូរផងដែរ។ តាមការចុះសិក្សាដោយផ្អែកលើទិន្នន័យឃុំ និងស្រុកបានឱ្យដឹងថា គោ ក្របីសរុបចំនួន ៨៥៧ក្បាល ក្រៅពីនោះមានជ្រូកសរុបចំនួន ៣៦០ក្បាល មាន់សរុប ១៣៣៦ក្បាល ទាសរុបចំនួន ៣៤២ក្បាល។ ចំពោះមធ្យោបាយផ្សេងៗក្នុងឃុំពពក មានដូចជា ម៉ូតូមានចំនួន ២៧៧គ្រឿងម៉ាស៊ីនកិនស្រូវខ្នាតតូច ៩កន្លែង ម៉ាស៊ីនភ្លើង ៤កន្លែង កង់ ៦២៤ គ្រឿង រទេះគោក្របី ៦៨៦ គ្រឿង។

**សេវាសាធារណៈ**

**១៩៦.** លទ្ធភាពនៃការប្រើប្រាស់សេវាសាធារណៈ (គមនាគមន៍, អគ្គិសនី , ការផ្គត់ផ្គង់ទឹកស្អាត , អប់រំ និងសុខាភិបាល) នៅក្នុងសហគមន៍នេះស្ថិតនៅក្រោមបន្ទាត់នៃតម្រូវការ។ ការចុះសិក្សាអង្កេតដោយផ្ទាល់បានបង្ហាញថា ផ្លូវគមនាគមន៍ដ៏សំខាន់សំរាប់ប្រជាពលរដ្ឋឃុំពពក ធ្វើដំណើរនិងដឹកជញ្ជូនទំនិញផ្សេងៗគឺផ្លូវលំពីឃុំមកកាន់ស្រុកស្ទោង ដែលជាផ្លូវសំខាន់។



Draft

១៩៧. ប្រជាជនដែលរស់នៅក្នុងឃុំពពក ពុំបានទទួលការផ្គត់ផ្គង់អគ្គិសនីជាមូលដ្ឋានទេ។ លទ្ធភាព នៃការប្រើប្រាស់ថាមពលក្នុងការដុតបំភ្លឺរបស់ប្រជាជននៅក្នុងតំបន់នេះមានកំរិតទាប ដោយពួកគាត់ភាគច្រើនប្រើចង្កៀងប្រេងកាត និងចន្លុះសំរាប់បំភ្លឺ ហើយមានប្រជាជនមួយចំនួនតូចប៉ុណ្ណោះមានលទ្ធភាពប្រើអាគុយ។ ដោយឡែកនៅក្នុងឃុំទាំងមូលមានម៉ាស៊ីនភ្លើង៤-៦គ្រឿង ម៉ាស៊ីនទាំងនេះពួកគាត់ប្រើសំរាប់បញ្ចូលអាគុយ និងសំរាប់តបំភ្លឺនៅពេលយប់តាមផ្ទះ (បញ្ចេះពីម៉ោង៦ល្ងាច ដល់ម៉ោង១០យប់) និងដាក់បញ្ចាំងវីដេអូក្នុងតូបលក់កាហ្វេ។ មានគ្រួសារប្រមាណ ៥០ភាគរយ មានវិទ្យុប្រើប្រាស់។ ចំណែកឯការចំអិនអាហារវិញគឺពួកគាត់ប្រើអុស ដែលរកបានពីព្រៃនៅក្បែរភូមិចំងាយ ប្រហែលពី០,៥-១គ.ម។

២១១. យើងនៅតែសង្កេតឃើញថា លទ្ធភាពប្រើប្រាស់ទឹកស្អាតរបស់ប្រជាជននៅមានកំរិត ប្រហាក់ប្រហែលនឹងតំបន់ដទៃទៀតដែរ។ តាមការចុះធ្វើអង្កេតផ្ទាល់ជាមួយប្រជាពលរដ្ឋបានឱ្យដឹងថាប្រជាពលរដ្ឋ នៅតាមភូមិនិមួយៗ មានគ្រួសារខ្លះប្រើប្រាស់ទឹកអណ្តូងជីកដៃដាក់លូ ដូចនេះហើយបានជាឃើញនៅក្នុងឃុំទាំងមូលមានចំនួន ១៣៤អណ្តូង និងអណ្តូងស្នប់ មានចំនួន ១៨៦ ឯមួយចំនួនទៀតគាត់ប្រើប្រាស់ទឹកអូរ ឬស្រះនៅពីមុខផ្ទះរបស់ពួកគាត់។ ចំពោះអណ្តូងស្នប់ឧបត្ថម្ភដោយធនាគារអភិវឌ្ឍន៍អាស៊ី ឯអង្គការសុខភាពផ្លូវចិត្តគ្មានព្រំដែន (PSF ONGD) អប់រំលើសុខភាព។ នៅរដូវប្រាំងប្រជាពលរដ្ឋមានការខ្វះខាតទឹកបរិភោគ ដោយសារទឹកអូរ និងទឹកអណ្តូងមួយចំនួនត្រូវបានរីងគោក ពុំមានទឹកសំរាប់បរិភោគគ្រប់គ្រាន់ទេ។ អាស្រ័យហេតុដូចនេះហើយ បានជាយើងឃើញមានមនុស្សឈឺច្រើន ជាពិសេសចំពោះកុមារតូចៗដែលបណ្តាលមកពីការហូបទឹកមិនស្អាត ដោយមិនបានដាំឱ្យពុះសម្លាប់មេរោគមុន នឹងយកទៅប្រើប្រាស់។

២១២. លទ្ធផលនៃការសិក្សាអង្កេតបានបង្ហាញថា លទ្ធផលនៃការសិក្សាអង្កេតបានបង្ហាញថា ក្នុងឃុំពពកមានអនុវិទ្យាល័យមួយខ្នងមាន៣បន្ទប់ និងមានសាលាបឋមសិក្សា៣ខ្នងមាន១៤បន្ទប់ មានគ្រូថ្នាក់អនុវិទ្យាល័យចំនួន៥នាក់ និងគ្រូបង្រៀនថ្នាក់បឋមសិក្សាចំនួន១០នាក់។ ប៉ុន្តែសិស្សដែលបានមករៀនមិនបានគ្រប់គ្នាទេ មួយចំនួនបានជួយធ្វើការឪពុកម្តាយតាមចំការនៅឆ្ងាយពីផ្ទះ និងខ្វះខាតខាងជីវភាពដែលជាហេតុធ្វើឱ្យការសិក្សារបស់ពួកគេមិនបានជាប់លាប់ល្អ។

២១៣. នៅក្នុងឃុំពពកមិនមានប៉ុស្តិ៍សុខភាពនៅឡើយទេ នៅពេលមានអ្នកជំងឺម្តងៗ ត្រូវបញ្ជូនទៅមណ្ឌលសុខភាពស្ទោងតែម្តង។ ដោយពុំមានថ្នាំសង្គ្រោះគ្រប់គ្រាន់សំរាប់អ្នកជម្ងឺទូទៅទេ គឺមានតែថ្នាំជម្ងឺគ្រុនចាញ់បន្តិចបន្តួចតែប៉ុណ្ណោះ។ បច្ចុប្បន្ននេះអ្នកភូមិទាំងអស់នៅពេលមានជម្ងឺ ឈឺធ្ងន់ម្តងៗគាត់បញ្ជូនអ្នកជម្ងឺទៅខេត្តសៀមរាប ព្រោះវានៅទីនោះមានដែលព្យាបាលមិនគិតប្រាក់។ ចំណែកឯអ្នកមានផ្ទៃពោះវិញទោះបីជាមានពេទ្យនៅប្រចាំការក្នុងមណ្ឌលសុខភាពស្រុកក្តី ក៏ពួកគាត់មួយចំនួនធំនៅមានជំនឿលើឆ្មបបុរាណនៅឡើយ នៅក្នុងភូមិនិមួយៗយ៉ាងហោចណាស់ក៏មានឆ្មប បុរាណពីរទៅបីនាក់ដែល ទទួលការបណ្តុះបណ្តាលតិចតួច។

### ប្រភពធនធានធម្មជាតិ និងលទ្ធភាពនៃការទទួលយកធនធានធម្មជាតិ

**២១៤.** ធនធានព្រៃឈើដែលប្រជាជនទទួលយកបានមានដូចជា ឈើមូល ផ្លែឈើ ឬស្សី ទំពាំង រកផ្សិត និងការនេសាទត្រីបន្តិចបន្តួចនៅតាមស្ទឹងស្ទោង និងអូរជាដើម។ តាមការសិក្សាយើងទទួលបានថាព្រៃឈើមានការធ្លាក់ចុះយ៉ាងខ្លាំងក្នុងរយៈពេល២ទស្សវត្សចុងក្រោយនេះ ដោយសារការកាប់ព្រៃយ៉ាងអាណាធិបតេយ្យហើយបច្ចុប្បន្ននេះឈើដែលមានតំលៃពាណិជ្ជកម្មនៅសេសសល់មិនច្រើនទេ (សម្តីអះអាង របស់ប្រជាជន ដែលបានចូលរួមពិគ្រោះយោបល់)។

### ប្រភពចំណូលសំខាន់របស់គ្រួសារ

**២១៥.** តាមរយៈការចុះសិក្សាដោយផ្ទាល់ជាមួយប្រជាពលរដ្ឋនៅទីនោះបង្ហាញថា ផលិតផលចំការស្វាយចន្ទីជាប្រភពចំណូលសំខាន់របស់គ្រួសារទីមួយៗ។ តែផ្ទៃដីសំរាប់ធ្វើស្រែមានតិចតួច មិនអាចផ្តល់ឱ្យគ្រប់គ្រួសារឡើយ គ្រួសារដែលគ្មានដីស្រែបានទៅរានដីធ្វើចំការទៅតាមលទ្ធភាពរៀងៗខ្លួន។ គ្រួសារភាគច្រើនដាំស្វាយចន្ទី ទិន្នផលនៃមុខដំណាំនេះអាចធ្វើឱ្យប្រជាជននៅក្នុងតំបន់នេះមានជីវភាពធូរធារមួយកំរិត ក្នុងរយៈពេលពីឆ្នាំមុននេះ(២០០៩) ដែលតំលៃក្នុង១គីឡូក្រាមលក់បានក្នុងតំលៃ ២៥០០-៣០០០រៀល។ ក្រៅពីនោះពួកគាត់ប្រកបរបរកាប់អុស និងកាប់ឈើនៅក្នុងតំបន់អភិរក្ស។ ចំណូលដែលបានមកពីការធ្វើចំការ និងចំការស្វាយចន្ទីនេះក៏នៅតែមិនអាចទ្រទ្រង់នូវជីវភាពក្នុងគ្រួសាររបស់ពួកគាត់ល្អទេ ព្រោះគ្រួសារភាគច្រើនមានសមាជិកច្រើន ហើយការដាំដំណាំចន្ទីរបស់ពួកគាត់មានលក្ខណៈជាយថាផល។ ចំណែកឯទិន្នផលស្រូវដែលទទួលបាននៅមានកំរិតទាបនៅឡើយគិតជាមធ្យមគឺ១-១,៥ តោន ក្នុង១ឆ្នាំមួយហិកតា ចំពោះស្វាយចន្ទីមាន ៥០០-៧០០ដើម/ហិកតា) ដូចនេះមួយឆ្នាំអាចទទួលបានប្រមាណ ២.៥០០.០០០-៣.១៥០.០០០រៀល (តាមការសាកសួរជាមួយលោក ជាង តឿ ក្រុមប្រឹក្សាឃុំពពក)។

**២១៦.** ក្រៅពីរបរកសិកម្ម និងកាប់ឈើ ប្រជាពលរដ្ឋមួយចំនួនបានចិញ្ចឹមសត្វជាលក្ខណៈគ្រួសារ ដើម្បីផ្គត់ផ្គង់ជីវភាពគ្រួសារបន្ថែមទៀត។ តាមទិន្នន័យដែលទទួលបានពីមេឃុំបានបង្ហាញថា ការចិញ្ចឹមជ្រូក តិចឬច្រើនគឺអាស្រ័យទៅលើលទ្ធភាព និងកំលាំងពលកម្មនៃគ្រួសារនិមួយៗ។ មានគ្រួសារចំនួន១០% មានលទ្ធភាពចិញ្ចឹមជ្រូកពី២-៤ក្បាល ប្រជាពលរដ្ឋ១៥%មានលទ្ធភាពចិញ្ចឹមពី១-២ក្បាល និងប្រជាជនរហូតដល់៧៥% មានលទ្ធភាពចិញ្ចឹមជ្រូកបានតែ១-២ក្បាលប៉ុណ្ណោះ។ ពួកគាត់អាចលក់ជ្រូករស់បានតំលៃ៣.០០០រៀល ក្នុងមួយគីឡូក្រាម ឱ្យទៅឈ្មួញកណ្តាលដែលចូលមកទិញដល់ផ្ទះ។ ក្រៅពីនេះពួកគាត់បានចិញ្ចឹមមាន់ទា ព្រោះវាមានលក្ខណៈងាយស្រួលក្នុងការចិញ្ចឹម ដោយមិនចាំបាច់ចំណាយច្រើនក្នុងការផ្តល់ចំណីនិងថែទាំ ហើយពួកគាត់អាចលក់មាន់បានក្នុង១គីឡូក្រាមតំលៃ១៥.០០០រៀល-១៧.០០០រៀល ទាសំពៅមួយលក់បានតំលៃ ១០០០០រៀល ឯទាកាប៉ាមួយមានតំលៃ១៥០០០-៣០០០០រៀល។ ក្រៅពីនេះពួកគាត់បានចូលព្រៃដើម្បី

កាប់ឈើមូល អុស រកវល្លិ៍ ផ្តៅ ទំពាំង កាប់ឬស្សី នេសាទត្រីតាមស្ទឹង អូរ និងដាក់អន្ទាក់សត្វ ដើម្បីផ្គត់ផ្គង់តំរូវការបន្ថែមក្នុងគ្រួសារ។ បច្ចុប្បន្ននេះពួកគាត់បានកាប់ឈើធ្នង់យកទៅលក់នៅស្ទោង ដោយដឹកតាមម៉ូតូ ឬគោយន្ត។

**វិបត្តិដែលធ្វើអោយលទ្ធភាពទិញដូររបស់គ្រួសារធ្លាក់ចុះ**

**២១៧.** នៅក្នុងសហគមន៍ ដែលក្រុមការងារបានចុះធ្វើការអង្កេត បានបង្ហាញអោយឃើញអំពីរូបភាពនៃវិបត្តិដែលកើតមានឡើងនៅក្នុងសហគមន៍ទាំងនេះហាក់ដូចជា មានលក្ខណៈខុសគ្នាទៅនឹងតំបន់ភូមិភាគកណ្តាលនៃប្រទេស។ ករណីអាសន្នដែលកើតមានចំពោះសហគមន៍ទាំងនោះមានដូចជាៈ

- ការធ្វើស្រែចំការតាមបែបបុរាណគឺអាស្រ័យទឹកភ្លៀង ជាហេតុដែលធ្វើឱ្យប្រជាពលរដ្ឋប្រមាណ ៣០ភាគរយហូបមិនគ្រប់គ្រាន់ខ្វះស្បៀងក្នុងរយៈពេល២-៦ខែ។
- ដីស្រែធ្វើតែស្រូវមួយមុខមិនបានផ្លាស់ប្តូរមុខដំណាំដែលទាញយកផលតែពីដីហើយមិនបានផ្តល់ជីជាតិទៅឱ្យដីវិញទាល់តែសោះធ្វើឱ្យដីកាន់តែរិចរឹលទៅៗ។
- ដីមានជីជាតិបង្គួរ ប៉ុន្តែប្រជាពលរដ្ឋពុំទាន់យល់ដឹងខាងផ្នែកកសិកម្ម ធ្វើអោយទិន្នផលស្រូវកាន់តែថយទៅៗ។
- ចំណុចមួយទៀតដែលគួរឱ្យកត់សំគាល់ផងដែរ គឺឆ្នាំនេះ(២០១០) ធម្មជាតិមិនបានអំណោយផលមិនមានភ្លៀងដើមឆ្នាំធ្វើឱ្យពួកគាត់មានការព្រួយបារម្ភអំពីដំណាំរបស់ពួកគាត់ពិសេសការធ្វើស្រែ ។ល។
- ចំណែកឯបញ្ហាសុខភាពក៏នៅតែជាបញ្ហាចោទមួយដ៏សំខាន់ ដែលប្រជាជននៅតំបន់នេះកំពុងតែប្រឈមមុខដោយសារសេវាសុខភាពនៅមានកំរិតទាបនៅឡើយ។ ក្នុងករណីមានសមាជិកណាម្នាក់ធ្លាក់ខ្លួនឈឺធ្ងន់ធ្ងរ ដែលសេវាសុខភាពតាមមូលដ្ឋានមិនមានលទ្ធភាពគ្រប់គ្រាន់ ទើបតំរូវឱ្យពួកគាត់បង្ខំចិត្តបញ្ជូនទៅមន្ទីរពេទ្យក្រុងអង្គរខេត្តសៀមរាប ឬពេទ្យបង្អែកខេត្តកំពង់ធំ ហើយទន្ទឹមនឹងនោះដែរ ដើម្បីដោះស្រាយរាល់វិបត្តិទាំងនោះ ពួកគាត់បានប្រើគ្រប់មធ្យោបាយ ទាំងអស់ទៅតាមលទ្ធភាព ដែលអាចធ្វើទៅបានដូចជាៈ ខ្ចីបុលស្រូវពីអ្នកដទៃ ដាក់ស្រែបញ្ចាំ ចងការប្រាក់ លក់ស្រូវអង្ករ លក់គោ ក្របី ជាដើម។ ទាំងនេះជាយុទ្ធសាស្ត្រមួយ ដើម្បីដោះ ទ័លនៅពេលដែលជួបប្រទះនូវវិបត្តិសេដ្ឋកិច្ចក្នុងគ្រួសារ។

**សហគមន៍ព្រៃឈើ**

**២១៨.** ការសិក្សាបានបង្ហាញអោយឃើញថា នៅក្នុងតំបន់ដែលក្រុមហ៊ុនស្នើសុំនេះមិនមានការពាក់ព័ន្ធជាមួយនឹងព្រៃសហគមន៍។ ព្រោះដីនេះជាដីស្ថិតនៅក្នុងតំបន់ដែនជំរកសត្វព្រៃបឹងពែរ ពួកគាត់បានប្រាប់ថា



Draft

មានពាក់ព័ន្ធ នឹងប្រភពប្រើប្រាស់ទឹករបស់គាត់ក្នុងការធ្វើស្រែ ពិសេសនៅតំបន់ទ្រនាប់មាត់អូរត្រូវបានក្រុមហ៊ុនឈូសឆាយអស់ធ្វើឱ្យក្រខ្វក់ដល់ប្រភពទឹកទាំងនោះ សំរាប់ប្រើប្រាស់និងសត្វពាហនៈផឹក។ ស្នើសុំឱ្យមានការរក្សាទុកតំបន់មាត់ដំបូកជ្រាបដើម្បីធ្វើការអភិរក្សជីវចំរុះ និងរក្សាទុកសម្រាប់ជាប្រយោជន៍ដល់ប្រជាពលរដ្ឋទូទាំងឃុំប្រើប្រាស់នៅរដូវប្រាំង។

**តំបន់គ្រប់គ្រងពិសេស**

**២១៩.** តាមការសាកសួរលោកមេឃុំ និងស្មៀន បានមានប្រសាសន៍ថា នៅក្នុងឃុំនេះមានតំបន់គ្រប់គ្រងពិសេសដូចជាៈ តំបន់ព្រៃអារក្ស ដូចជាទួលបន្ទាយព្រះពុទ្ធ ដែលទីនោះជាកន្លែងដែលលោកសង្ឃមួយចំនួនចូលទៅធ្វើវិបស្សនាធុរៈមានទំហំប្រមាណ១ហិកតា និងត្រពាំងអរជូនប្រមាណជា៣ហិកតា ដែលត្រពាំងនេះមានជាប់ទាក់ទងនឹងប្រវត្តិអរជូនរត់មកស្លាប់នៅទីនោះផងដែរ តាមការនិយាយរបស់អ្នកភូមិ និងលោកមេឃុំពពក តែបច្ចុប្បន្នក្រុមហ៊ុនបានឈូសឆាយលប់អស់ហើយ។

**ហេតុប៉ះពាល់នៃការអនុវត្តគំរោងកសិ-ឧស្សាហកម្មទៅលើជីវភាពរស់នៅរបស់សហគមន៍ និងការទទួលយករបស់មូលដ្ឋានចំពោះគំរោងអភិវឌ្ឍន៍ :**

Draft

យោងលើលទ្ធផលនៃការសិក្សាពិគ្រោះយោបល់ជាមួយថ្នាក់ដឹកនាំខេត្ត ស្រុក មន្ទីរ ឃុំ ភូមិ ដែលពាក់ព័ន្ធបានបង្ហាញថាៈ

**២២០.** ថ្នាក់ដឹកនាំខេត្ត ស្រុក មន្ទីរ/ស្ថាប័នពាក់ព័ន្ធៈ ក្នុងករណីដែលរាជរដ្ឋាភិបាលធ្វើការប្រទានសិទ្ធិអោយក្រុមហ៊ុនធ្វើការវិនិយោគលើដំណាំកសិ-ឧស្សាហកម្ម នោះនឹងនាំមកនូវផលប្រយោជន៍ពហុវិជ្ជមានច្រើនយ៉ាងទាំងលើវិស័យសេដ្ឋកិច្ច សង្គម និងបរិស្ថាន។ ទោះបីជាពួកគាត់មិនអាចផ្តល់ពតិមានលំអិតពាក់ព័ន្ធនិងផលប្រយោជន៍ទាំងនេះក្តី តែពួកគាត់បានសំដែងសេចក្តីបារម្ភអំពីការធ្លាក់ចុះនិងបន្តបាត់បង់ធនធានព្រៃឈើដោយសារការទន្ទ្រានយកដីធ្លីធ្វើកម្មសិទ្ធិតាមគ្រប់រូបភាពតូចធំ និងសកម្មភាពប្រមូលផលព្រៃឈើដែលបាននឹងកំពុងបន្តយ៉ាងអនាធិបតេយ្យក្នុងរូបភាពឆ្នក់លួចលាក់។

**២២១.** ជាការពិតណាស់ដែលថាការអភិវឌ្ឍន៍តែងតែមានចំណុចអវិជ្ជមាន និងការខ្វែងគំនិតគ្នារវាងវិនិយោគិនជាមួយអាជ្ញាធរនិងសហគមន៍មូលដ្ឋាន ឬរវាងវិនិយោគិននិងអាជ្ញាធរ ជាមួយអង្គការសង្គមស៊ីវិល និងសហគមន៍មូលដ្ឋាន ទៅលើផលប្រយោជន៍រួមមួយដែលទាំងអស់គ្នាមានសិទ្ធិក្នុងការទទួលបាន ប៉ុន្តែទិសដៅនិងគោលបំណងរួមរបស់ពួកយើង គឺសំដៅធ្វើយ៉ាងណាដើម្បីទទួលបាននូវការអភិវឌ្ឍន៍នៅកម្ពុជាមួយដែលធានាបាននូវកំណើន និងការអភិវឌ្ឍន៍ជាពិសេសសម្រាប់ការអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធជាយុទ្ធសាស្ត្រ ដែល

ក្នុងនោះត្រូវពង្រឹងនិងលើកកំពស់ជីវភាពរស់នៅរបស់សហគមន៍មូលដ្ឋាន ក្នុងក្របខ័ណ្ឌមួយដែលមានលក្ខណៈអាចទទួលយកបានទាំងផ្នែកសង្គម-បរិស្ថាន និងមានប្រសិទ្ធិភាពសេដ្ឋកិច្ច ។

**២២២.** បន្ទាប់ពីមានការជួបប្រជុំពិគ្រោះយោបល់ជាមួយប្រជាជនទាំងអស់រួចមក លទ្ធផលបានបង្ហាញអោយឃើញថា ប្រជាជននៅក្នុងឃុំពពក ភូមិសំបួរ ភូមិ អន្លង់ក្រាញ់ ភូមិ កោះសំរោង ភូមិស្រែក្រសាំង ភូមិខ្ចមមន ភូមិពពក ភូមិផ្ទះដើម ភូមិត្រពាំងឬស្សី **(រូបភាពក្នុង ឧបសម្ព័ន្ធ៧)** មួយចំនួនមានសេចក្តី សោមនស្សរីករាយនឹងទទួលយកគំរោងអភិវឌ្ឍន៍ដំណាំកសិ-ឧស្សាហកម្ម លើដីសម្បទានសេដ្ឋកិច្ចរបស់ក្រុមហ៊ុន ហើយមួយចំនួនទៀតមិនព្រមទទួលយកការអភិវឌ្ឍន៍របស់ក្រុមហ៊ុនឡើយ ពួកគាត់គិតថាវានឹងបាត់បង់ផល-អនុផលព្រៃឈើដែលគាត់ធ្លាប់ទទួលពីមុនមក។ ចំពោះប្រជាជន ដែលទទួលយកការអភិវឌ្ឍន៍នោះពួកគាត់បានសំណូមពរធ្វើយ៉ាងណាកុំអោយបាត់បង់ ឬប៉ះពាល់ដល់ផលប្រយោជន៍ប្រជាពលរដ្ឋ ហើយរក្សាព្រៃដែនបំរុងសម្រាប់គោក្របី ព្រៃអារក្ស ព្រៃបំរុងទុកសម្រាប់កូនចៅ ជំនាន់ក្រោយរបស់ពួកគាត់ និងជួយធ្វើការអភិវឌ្ឍន៍ និងជាពិសេស ដីព្រៃនៅតាមតំបន់ទ្រនាប់មាត់អូរដំបូកជ្រាប និងអូរក្រសាំង ។

**២២៣.** ក្នុងឱកាសចូលរួមពិគ្រោះយោបល់ បងប្អូនតំណាងអោយប្រជាជនក្នុងសហគមន៍ទាំងមូល បានមានមតិ និងសំណូមពរដូចខាងក្រោមៈ

- លោក **សម សាង** មេឃុំពពក : ចំពោះក្រុមហ៊ុន C.R.C.K.2 APHIVATH CAOUT CAOUC CO., LTD. ក្នុងតំបន់យើងខ្ញុំមានការពាក់ពន្ធ័ ប្រជាជនមួយចំនួនមានការដីស្រែចំការ( ស្វាយចន្ទី) ដែលគាត់កំពុងធ្វើរាល់ថ្ងៃ( តែក្រុមហ៊ុនធ្វើការដោះស្រាយរួចស្រេចអស់ហើយ) តែអ្វីដែលនៅសេសសល់ គឺប្រព័ន្ធផ្លូវទឹក និងប្រភពទឹកសំរាប់ប្រើប្រាស់ធ្វើស្រែ ( មានដីស្រែរបស់ប្រជាពលរដ្ឋមួយចំនួននៅតាមមាត់អូរដំបូកជ្រាប និងអូរក្រសាំង) និងទឹកសំរាប់គោក្របីផឹក។ ជាសំណូមពរសូមឱ្យក្រុមហ៊ុនធ្វើការដោះស្រាយជាមួយប្រជាពលរដ្ឋឱ្យបានសមស្រប សុំឱ្យក្រុមហ៊ុនឈូសថយពីព្រំមាត់អូរយ៉ាងហោចណាស់ឱ្យបានចំងាយ៣០-៥០ម៉ែត្រពីមាត់អូរ នឹងមិនត្រូវឈូសឈើទំលាក់ចូលអូរទាំងនោះឡើយ ពិសេសទំលាក់ចូលទៅក្នុងស្រែរបស់ពួកគាត់។ សុំឱ្យសង់សាលារៀន ប៉ុស្តិ៍សុខភាព អណ្តូងទឹកស្អាត ជាចុងក្រោយសុំធ្វើយ៉ាងណាគិតគូរពីសុខភាពរបស់ប្រជាពលរដ្ឋនៅក្នុងតំបន់នេះឱ្យបានច្រើនផង ព្រោះពួកគាត់ប្រើប្រាស់ប្រភពទឹកទាំងនោះប្រចាំថ្ងៃ( ទាំងសត្វ និងមនុស្ស) ។
- លោក **ជាង តឿ** ក្រុមប្រឹក្សាឃុំ : ចំពោះការស្នើសុំដីសម្បទាន ដែលក្រុមហ៊ុនកំពុងអភិវឌ្ឍន៍ប៉ះពាល់ដីស្រែចំការរបស់ប្រជាពលរដ្ឋ ចំនួនជាង៤០គ្រួសារចំការស្វាយចន្ទី តែក្រុមហ៊ុនដោះស្រាយដីស្រែចំការនោះរួចរាល់អស់ហើយ ។ សំណូមពរសុំឱ្យធ្វើផ្លូវសំរាប់ក្រុមហ៊ុនមួយដោយឡែក ព្រោះសព្វថ្ងៃក្រុមហ៊ុនបើកបរលើផ្លូវដែលជាអំណោយរបស់ឯកឧត្តម ងួន ញ៉ិល ដូចនេះហើយរដូវវស្សាអាចខូចបើខូចមិនងាយនឹងមានថវិការជួសជុលវិញទេ ហើយនៅតំបន់នេះ ទើបតែមានផ្លូវស្រួលធ្វើដំណើរទេ

ពីមុនមកគឺពិបាកធ្វើដំណើរចេញចូលទៅមកណាស់ ដូចនេះក្រុមហ៊ុនគួរធ្វើផ្លូវមួយដោយឡែកវិញ កុំឱ្យខូចផ្លូវចាស់នេះ ហើយក្រុមហ៊ុនកុំឈូសយកឈើទៅទំលាក់ក្នុងប្រព័ន្ធអូរធ្វើឱ្យកកស្ទះ និងក្រខ្វក់ទឹកពិបាកប្រើប្រាស់ និងគោក្របីផឹក។

- លោក **រចំ សឿន** មេភូមិពពក : បើអភិវឌ្ឍន៍តំបន់ក្នុងតំបន់យើងខ្ញុំ មែននោះធ្វើឱ្យប្រជាជនមានការងារធ្វើ ប៉ុន្តែប៉ះពាល់នឹងការទទួលប្រយោជន៍ពីផល និងអនុផលព្រៃឈើដែលធ្លាប់ទទួលបានប្រចាំថ្ងៃ ឈើសំរាប់ធ្វើជាសំណង់ផ្ទះសំបែងលែងមានតទៅទៀត។ ជាសំណូមពរសូមឱ្យក្រុមហ៊ុនធ្វើការដោះស្រាយជាមួយប្រជាពលរដ្ឋឱ្យបានសមស្រប ហើយសុំឱ្យក្រុមហ៊ុនជួយធ្វើផ្លូវ សង់សាលារៀន ប៉ុស្តិ៍សុខភាព អណ្តូងទឹកស្អាត។
- ប្រជាពលរដ្ឋតំណាងភូមិសំបូរ : ពួកគាត់មិនចង់ឱ្យបានក្រុមហ៊ុនចូលមកអភិវឌ្ឍន៍ទេ ពីព្រោះពួកគាត់ខ្លាចបាត់បង់ដីស្រែចំការ ព្រៃឈើ និងសត្វព្រៃ ហើយនៅពេលដែលក្រុមហ៊ុនចូលមក គេឈូសឆាយដីព្រំហ៊ុំព័ទ្ធជិតរួចជីកប្រឡាយជុំវិញធ្វើឱ្យគោក្របីរបស់ពួកគាត់ធ្លាក់ចូលស្លាប់។

ជាពិសេសទៅទៀតនោះ កូនចៅគាត់ជំនាន់ក្រោយលែងស្គាល់សត្វ លែងស្គាល់ឈើធ្វើផ្ទះ និងដីចំការស្រែ ដីលំនៅដ្ឋានទៀត ហើយ។